# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ ៖ ០៥ សរ**

# សារាចរ
## ស្តីពី
## ការបើកប្រាក់សោធនសម្រាប់និវត្តន៍ជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ យោធិនចូលនិវត្តន៍ យោធិនបាត់បង់សមត្ថភាពពលកម្ម ដែលកំពុងទទួលមុខតំណែងក្នុងមុខងារនយោបាយ

កន្លងមករាជរដ្ឋាភិបាល បានពិនិត្យឃើញថា អតីតមន្ត្រីរាជការ រួមមាននិវត្តន៍ជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអតីតយុទ្ធជន រួមមានយោធិនចូលនិវត្តន៍ យោធិនបាត់បង់សមត្ថភាពពលកម្ម ដែលមានបទពិសោធន៍និងស្នាដៃបម្រើជាតិមាតុភូមិត្រូវបានផ្តល់មុខតំណែងក្នុងមុខងារនយោបាយនៅតាមក្រសួង ស្ថាប័ន ក្រុងប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។

ដោយអនុលោមតាមបទបញ្ញត្តិ និងលិខិតបទដ្ឋានដែលនៅជាធរមាននិងក្នុងគោលបំណងដើម្បីពង្រឹងការអនុវត្តន៍គោលនយោបាយអភិបាលកិច្ចល្អឱ្យមានប្រសិទ្ធភាព រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅ ៖

១- គ្រប់ក្រសួង ស្ថាប័ន ត្រូវផ្តល់បញ្ជីរាយនាម និវត្តន៍ជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ យោធិនចូលនិវត្តន៍ យោធិនបាត់បង់សមត្ថភាពពលកម្ម ហើយបច្ចុប្បន្នទទួលមុខតំណែងក្នុងមុខងារនយោបាយ ទៅក្រសួងសង្គមកិច្ច អតីត យុទ្ធជន និងយុវនីតិសម្បទា ឱ្យបានឆាប់បំផុតជាកំហិត ។

២- ចំពោះនិវត្តន៍ជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ យោធិនចូលនិវត្តន៍ យោធិនបាត់បង់សមត្ថភាពពលកម្មទាំងឡាយណាដែលកំពុងទទួលទាំងប្រាក់សោធនប្រចាំខែ និងទាំងប្រាក់ឧបត្ថម្ភក្នុងមុខងារនយោបាយ ក្នុងពេលជាមួយគ្នា ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាត្រូវផ្អាកការបើកប្រាក់សោធនជាបន្ទាន់ ។ ប្រាក់សោធនទាំងនេះ និងប្រាក់សោធនដែលបានបើករួចហើយ ជូននិវត្តន៍ជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ យោធិនចូលនិវត្តន៍ យោធិនបាត់បង់សមត្ថភាពពលកម្មដែលកំពុងទទួលមុខតំណែងក្នុងមុខងារនយោបាយត្រូវបង្វែរចូលថវិការជាតិវិញជាកំហិត ។

និវត្តន៍ជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ យោធិនចូលនិវត្តន៍ យោធិនបាត់បង់សមត្ថភាពពលកម្ម អាចជ្រើសរើសយកប្រាក់ឧបត្ថម្ភណាមួយដែលខ្ពស់ជាងគេក្នុងចំណោមប្រាក់ឧបត្ថម្ភច្រើនកន្លែង ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តទៅតាមនីតិវិធី ។

៣- បន្ទាប់ពីបញ្ចប់មុខតំណែងក្នុងមុខងារនយោបាយ និវត្តន៍ជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ យោធិនចូលនិវត្តន៍ យោធិនបាត់បង់សមត្ថភាពពលកម្ម ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងសង្គមកិច្ចអតីតយុទ្ធជន និង យុវនីតិសម្បទា ដើម្បីបានទទួលប្រាក់សោធនប្រចាំខែចាប់ពីពេលបញ្ចប់មុខតំណែងក្នុងមុខងារនយោបាយតទៅ។ ប្រាក់សោធនប្រចាំខែដែលត្រូវបានផ្អាកក្នុងរយៈពេលកាន់មុខតំណែងក្នុងមុខងារនយោបាយមិនត្រូវបានគិតរំលឹកជូនវិញឡើយ ។

គ្រប់ក្រសួង ស្ថាប័ន ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវសហការអនុវត្តសារាចរនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

វាយអត្ថបទដោយ ៖ លោក ឈឹម ទីណា